ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១៣៦ ប្រ.ប.ទ.

...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព...

# ប្រកាស

## ស្តីពីការ បង្កើតក្រុមការងារ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញលិខិតលេខ ៣៦ សសរ ចុះថ្ងៃ ២២ ខែ ឧសភា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារមួយ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដើម្បីសហការ ការងារ ជាមួយក្រុមការងារទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការត្រួតពិនិត្យ និង ឃ្លាំមើលទៅលើសកម្មភាព និងលទ្ធផលអនុវត្តការងារ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមាន សមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | ឡា | ណារ៉ាត | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | ទូច | ហេង | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-ឯកឧត្តម | មាស | ប៉ូ | អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤-ឯកឧត្តម | ព្រុំ | សុគ្គារ | អគ្គនាយករដ្ឋបាល | សមាជិក |

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៥១០/៤២៦៥១០ ទូរសារ: (៨៥៥) ២៣-៤២៦៩៥២/៤២៦០១១

| | | | |
|---|---|---|---|
| ៥-លោក | **កែវ វុឌ្ឍិន** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៧-លោក | **ញាណ ស្រស់** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៧-លោក | **ទេព ប៊ុន្នា** | ប្រធាននាយកដ្ឋានផែនការហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ :** ក្រុមការងារ ខាងលើនេះ មានភារកិច្ច :

-សហការការងារជាមួយ ក្រុមការងារ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីត្រួតពិនិត្យ និង ឃ្លាំមើលទៅលើ សកម្មភាព និងលទ្ធផលអនុវត្តការងារ របស់ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

-ចប់ភារកិច្ច ត្រូវរាយការណ៍ពីលទ្ធផលការងារ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ។

**ប្រការ ៣ :** ក្រុមការងារខាងលើ នេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ***ឯកឧត្តមប្រធាន*** និង ចាត់តាំងអនុគណៈកម្មការជំនាញផ្សេងទៀត តាមការងារចាំបាច់ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ នាយកដ្ឋានពាក់ព័ន្ធ និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត ឱ្យមានប្រសិទ្ធិភាព តាមខ្លឹមសារ នៃ ប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ភ្នំពេញ , ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

**រដ្ឋមន្ត្រី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៥ " ដើម្បីអនុវត្ត "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ